**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០០២/០៩ របក.អគ**

**របាយការណ៍ ស្តីពី សកម្មភាពការងារប្រចាំខែ ធ្នូ ឆ្នាំ ២០០៨**
**របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត**

ក្នុងខែ ធ្នូ ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ក. ការងាររដ្ឋបាល**

-លិខិតស្នើសុំបញ្ជូនមន្ត្រីរាជការនៃអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវតម្លើងបៀវត្សប្រចាំឆ្នាំ២០០៩

-លិខិតស្នើសុំបញ្ជូនមន្ត្រីរាជការ ចំនួន ២រូប នៃអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវចូលរួមអបអរសាទរ ថ្ងៃប្រារព្ធខួបលើកទី៣០ នៃទិវាជ័យជំនះ ៧មករា២០០៩

-លិខិតស្នើសុំបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ផ្លូវដឹកនាំ និងមន្ត្រីក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដើម្បីចូលរួមសិក្ខាសាលាស្តីពីរបកគំហើញ ក្នុងរបាយការណ៍ស្តីពីប្រសិទ្ធិភាព និងហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ និងការបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការ និងការបង្កើនគណនេយ្យភាពទ្វេរទិស នៅខេត្តសៀមរាប នៅថ្ងៃទី៣០-៣១ ខែធ្នូ ឆ្នាំ២០០៨

-បានទទួលលិខិតសុំជួយអន្តរាគមន៍ក្នុងការតំឡើងប្រាក់បំណាច់មុខងារបន្ថែមជូន ក្រឡាបញ្ជីពីប្រធានសាលាដំបូងក្រុងភ្នំពេញ

-បានទទួលលិខិត អញ្ជើញនាយករងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីចូលរួមពិធីធ្វើសច្ចាប្រណិធានរបស់សិស្សចៅក្រម ជំនាន់ទី៤ ដើម្បីទៅធ្វើកម្មសិក្សានៅតាម សាលាជំរះក្តីនានា ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨

-បានទទួលលិខិតអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា នៃការអនុវត្តគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ នៅខេត្តកណ្តាល នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០៨

-បានទទួលលិខិតពីអគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដោយស្នើផ្តល់របាយការណ៍ស្តីពី វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពអភិបាលកិច្ចទី២ ប្រចាំឆ្នាំ២០០៨ លើវិស័យ "កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌" ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

## ខ. ការងារកំណែទម្រង់

-ប្រជុំក្រុមការងារ របស់អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដោយពិភាក្សាលើសិក្ខាសាលា ស្តីពីការស្ទង់មតិជាមូលដ្ឋាននៃសមត្ថភាពតាក់តែងច្បាប់របស់អង្គភាពនីតិកម្មនៅ តាមក្រសួងស្ថាប័ន និងរៀបចំបញ្ជីសំណួរសម្រាប់សិក្ខាសាលានោះ។

-ប្រជុំមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៨ ដោយបែងចែកក្រុមការងារសម្រាប់ សម្របសម្រួលនៅក្នុងក្រុម សម្រាប់សិក្ខាសាលាស្តីពីការស្ទង់មតិជាមូលដ្ឋាននៃសមត្ថភាពតាក់តែងច្បាប់របស់ អង្គភាពនីតិកម្មនៅតាមក្រសួងស្ថាប័ន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩។

-ចូលប្រជុំជាមួយឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងជំនួយជាមួយធនាគារពិភពលោក នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨។

-ជួបពិភាក្សាជាមួយតំណាង GTZ ដើម្បីពិភាក្សាអំពីលទ្ធភាពជួយឧបត្ថម្ភធ្វើសេចក្តីព្រាងក្រមរដ្ឋបាល

-ជួបជាមួយតំណាង DIHR (លោក Bent Vase និងលោក Tomas Martin) ដើម្បីពិភាក្សាពីសហប្រតិបត្តិការរវាងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ និង DIHR សម្រាប់ឆ្នាំ២០០៩ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨។

-ជួបជាមួយតំណាង AusAid (លោកស្រី Arthi Patel) ដើម្បីពិភាក្សាពីការជ្រើសរើស Team Leader ថ្មីរបស់គម្រោង CCJAPIII នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨។

## គ. ផ្សេងៗ

-ចូលរួមប្រជុំអន្តរក្រសួង។

## ២-សន្និដ្ឋាន

ក្នុងខែ ធ្នូ ឆ្នាំ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រង គម្រោងជាអង្គភាពប្រតិបត្តិ ទន្ទឹងនឹងការបន្តសកម្មភាពលើគម្រោង ដែលមានស្រាប់ដូចជាតុលាការគំរូ និងប្រព័ន្ធសូចនាករជាដើម កំពុងតែប្រឹងប្រែង ដើម្បីឱ្យចេញជារូបរាងនូវគម្រោងសហប្រតិបត្តិការជាមួយគម្រោង GTZ និងជួបជាមួយតំណាង DIHR ពិភាក្សាពីសហប្រតិបត្តិការរវាងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង DIHR។

៣-ទិសដៅអនុវត្តក្នុងខែមករា ឆ្នាំ២០០៩

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ អទឈ

-រៀបចំសិក្ខាសាលាស្តីពីការស្ទង់មតិជាមូលដ្ឋាននៃសមត្ថភាពតាក់តែងច្បាប់ របស់អង្គភាពនីតិកម្មនៅតាមក្រសួងស្ថាប័ន

-រៀបចំប្រជុំក្រុមប្រតិបត្តិគម្រោងលទ្ធភាពទទួលបានយុត្តិធម៌

-ត្រៀមទទួលគណៈប្រតិភូចុះមកវាយតម្លៃពាក់កណ្តាលអាណត្តិ សម្រាប់គម្រោងលទ្ធភាពទទួលបានយុត្តិធម៌

-ត្រៀមបំពេញឯកសារពាក់ព័ន្ធនឹងប្រសិទ្ធិភាពហិរញ្ញប្បទានសហប្រតិបត្តិការជូន លេខាធិការដ្ឋានគណៈ កម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨

អ្នកធ្វើរបាយការណ៍

ហ៊ីង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង